សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់
ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

១៣ វិច្ឆិកា ២០១៤

**សូមគោរព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ!**
**សូមគោរព លោកសំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តព្រះវិហារ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យា ផ្តល់ជំនួយឧបត្ថម្ភឥតសំណងរបស់រដ្ឋាភិបាលជប៉ុន សម្រាប់កែលម្អប្រព័ន្ធលូ និងផ្លូវក្នុងឃុំសង្កែពីរ ស្រុកឆែប ខេត្តព្រះវិហារ។

ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណដោយស្មោះសរចំពោះឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

គម្រោងនេះមានថវិកាសរុប ១០០,៩៧៣ ដុល្លាអាមេរិក ផ្តល់ជូនក្នុងគោលបំណងដើម្បីសម្រួលដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមដូចជា ការធ្វើដំណើរទៅកាន់សាលារៀន មណ្ឌលសុខភាព និងផ្សារ ក្នុងឃុំសង្កែពីរ ខេត្តព្រះវិហារដោយធ្វើការសាងសង់ប្រព័ន្ធលូចំនួនពីរ និងជួសជុលផ្លូវគ្រួសក្រហមប្រវែង៤,០០០ម៉ែត្រ។ ដោយសារទឹកជំនន់នៅរដូវវស្សា ប្រជាពលរដ្ឋប្រើប្រាស់ទូកដើម្បីឆ្លងកាត់ទន្លេត្រូវ ចំណាយពេលជាច្រើនម៉ោងដើម្បីធ្វើដំណើរទៅកាន់សាលារៀន មន្ទីរសុខាភាព និងផ្សារ។ យើងសង្ឃឹមថា គម្រោងនេះនឹងបង្កើនសមត្ថភាពគ្រប់គ្រងទឹកជំនន់ ព្រមទាំងកែលម្អបរិស្ថានឲ្យមានសុវត្ថិភាព ជាគុណប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ប្រមាណ១,៥០០នាក់។

ការដឹកជញ្ជូន គឺជាវិស័យដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បាននឹងកំពុងបន្តខិតខំប្រឹងប្រែងកែលម្អវិស័យនេះផងដែរ។

ខ្ញុំសង្ឃឹមថាគម្រោងនេះដែលយើងបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយនៅថ្ងៃនេះ នឹងត្រូវបានអនុវត្តដោយរលូន និងប្រកបដោយប្រសិទ្ធភាពដោយដៃគូរបស់យើងគឺមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ និងក្រុមប្រឹក្សាឃុំសង្កែពីរ ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីប្រជាជនកាន់តែច្រើន អាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងម៉ុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!